**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៩

## សេចក្ដីផ្ដើម

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារតាមតួនាទី ភារកិច្ចយ៉ាងសកម្មលើមុខងារស្នូលទាំងបី ដើម្បីផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

### ១- មុខងារនីតិកម្ម

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - គណៈកម្មាធិការអចិន្ត្រៃយ៍បើកកិច្ចប្រជុំចំនួន ០៣លើក ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន ០១លើក និងបើកសម័យប្រជុំពេញអង្គចំនួន ០១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖<br>១- ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤<br>២- ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍នៃព្រឹទ្ធសភា<br>៣- ស្ដាប់របាយការណ៍ស្ដីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់-ហេតុសង្ខេប និងពិស្ដារនៃកិច្ចប្រជុំគណៈកម្មាធិការ-អចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា<br>- បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់-ហេតុសង្ខេប និងពិស្ដារនៃកិច្ចប្រជុំគណៈកម្មាធិការ-អចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា<br>- បានថតចម្លងឯកសារចំនួន៧៤៧ច្បាប់ អស់ក្រដាសចំនួន១៩,៦៩៧សន្លឹក<br>- បានសម្អាត តុបតែងសាល ផ្ដល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុប |

| | |
|---|---|
| ចំនួន០៥ច្បាប់៖<br>៤.១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមីស្តីពី បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការហាមឃាត់អាវុធគីមី<br>៤.២-សេចក្តីព្រាងច្បាប់ស្តីពី សំណង់<br>៤.៣-សេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>៤.៤-សេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់<br>៤.៥-សេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម<br>- គណៈកម្មការជំនាញព្រឹទ្ធសភា បានបើកកិច្ចប្រជុំផ្ទៃក្នុង និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់។ | - បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍មកពីខាងក្រៅស្ថាប័នចំនួន១២០នាក់ ស្មើនឹង០៤លើក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន០៤លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន០៥លើក ស្មើនឹង០៥នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន១០ច្បាប់ពីរាជរដ្ឋាភិបាល និងរដ្ឋសភា ហើយបានចាត់ចែងតាមនីតិវិធី<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៤៧៣ច្បាប់ ហើយបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់<br>- បានបញ្ចូលព្រះរាជក្រម ព្រះរាជក្រឹត្យ និងអនុក្រឹត្យចំនួន១០៨ប្រធានបទ ទៅក្នុងវេបសាយច្បាប់ (Laws.gov.kh)<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៦លើក និងប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន២០លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន០៧លើក។ |

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានផ្ញើលិខិតបេសកកម្ម ជូនសមាជិក **សមាជិកា** ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការ**ដ្ឋាន** ព្រឹទ្ធសភាចំនួន៥៧នាក់ ស្មើនឹង១៨ច្បាប់<br>- បានផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងភេសជ្ជៈ សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ផ្សេងៗចំនួន០៣លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់សមាជិក សមាជិកាព្រឹទ្ធសភា បំពេញការងារតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន០២លើកៗ |

## ៣- មុខងារតំណាង

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាៈ<br>+ អញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍ពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់មាតុប្រទេសវិញរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត<br>+ អញ្ជើញជូននិងទទួលព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គយាងទៅបំពេញព្រះរាជកិច្ច និង | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ជាគណៈអធិបតីក្នុងពិធីផ្លូវការនានា និងកិច្ចប្រជុំផ្សេងៗសរុបចំនួន២០៦លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៩លើក<br>- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកា ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភាចំនួន៥២ច្បាប់ ស្មើនឹង១៥៨នាក់<br>- បានថតចម្លងឯកសារចំនួន៤,០៧៦ច្បាប់ អស់ក្រដាសចំនួន៦៣,៣២១សន្លឹក<br>- បានផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងភេសជ្ជៈ សម្រាប់ពិធីផ្សេងៗចំនួន០៣លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ |

យាងនិវត្តន៍ពីព្រះរាជាណាចក្រជប៉ុន មកកាន់មាតុប្រទេសវិញ

+ អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅបរិវេណព្រះឧបោសថរតនារាម ព្រះវិហារព្រះកែវមរកត ក្នុងបរិវេណព្រះបរមរាជវាំង

+ អញ្ជើញចូលថ្វាយបង្គំ និងនាំយកនូវបច្ច័យអង្គរ និងគ្រឿងសម្ភារបរិក្ខារផ្សេងៗថ្វាយសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដែលគង់ចាំព្រះវស្សាក្នុងពុទ្ធសីមាវត្តបទុមវតី នៅរាជធានីភ្នំពេញ

+ អញ្ជើញចូលរួមពិសាអាហារពេលល្ងាច ដើម្បីអបអរសាទរខួបលើកទី៧០ នៃថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅភោជនីយដ្ឋាន Tunglok Singanture

+ អញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរ កងកម្លាំង និងប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ

+ អញ្ជើញគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម Jacques Chirac អតីតប្រធានាធិបតី នៃសាធារណរដ្ឋបារាំង នៅស្ថានទូតបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

+ អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភាព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី សាយ ឈុំ

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៣០លើក ស្មើនឹង ១១១នាក់
- បានទទួលលិខិតចូលចំនួន១,០៣២ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៧៩ច្បាប់
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៤៩លើក ស្មើនឹង៨២នាក់
- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន ០៣លើក ស្មើនឹង០៧នាក់
- បានផ្តល់អត្ថបទព័ត៌មាន និងរូបភាពស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញសង្គមព្រឹទ្ធសភាចំនួន៤០លើក
- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៦០នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន៨០ក្បាល និងសងវិញចំនួន៨០ក្បាល
- បានផ្តល់សៀវភៅក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ជូនដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន០៣ក្បាល
- បានផលិតទស្សនាវដ្តីប្រចាំខែតុលា ឆ្នាំ២០១៩ ចំនួន២,៥០០ក្បាល
- បានផលិតវីដេអូ ស្តីពី ជំនួបសវនាការរបស់

| | |
|---|---|
| + អញ្ជើញប្រារព្ធពិធីសូត្រមន្តបុណ្យកឋិនទានសាមគ្គី នៅរាជធានីភ្នំពេញ និងដង្ហែអង្គកឋិនទានសាមគ្គីប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាសក្នុងពុទ្ធសីមា ដើម្បីប្រមូលបច្ច័យសាងសង់សមិទ្ធផលនានា ទុកជាគរុភណ្ឌក្នុងវត្តរង្សីនៅខេត្តព្រៃវែង<br>+ អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃងសុន្ទរកថាបើកវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភា នៅខេត្តពោធិ៍សាត់<br>+ អញ្ជើញជាអធិបតីក្នុងពិធីចែកអំណោយសម្ភារសិក្សាដល់សិស្សានុសិស្សចំនួន ៥០០នាក់ នៅសមាគមកុមារនៃក្តីសង្ឃឹមកម្ពុជា ខេត្តកណ្តាល<br>+ អញ្ជើញទស្សនាការប្រកួតបាល់ទាត់មិត្តភាពរវាងក្រុមយុវជនវត្តវាំរិន ហៅវត្តព្រែកលាបជាមួយក្រុមយុវជនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានចែកអំណោយសម្ភារកីឡាជូនដល់ក្រុមយុវជនវត្តវាំរិនមួយចំនួន ផងដែរ នៅទីលានបាល់ទាត់វិទ្យាល័យបឹងកេងកង ជា ស៊ីម<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំង ទៅពិនិត្យនិងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល។<br>- ក្រុមសមាជិកព្រឹទ្ធសភាបានធ្វើវេទិកាស្តីពីការពង្រឹងសមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធអាពាហ៍- | ចំនួន០៥លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន៣២១លើក<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សារបស់និស្សិតជំនាញវិស្វករ មកពីសាធារណរដ្ឋកូរ៉េ ចំនួន០៥នាក់។ |

ពិពាហ៍ និងគ្រួសារ សន្តិកម្ម និងការដោះស្រាយវិវាទក្រៅប្រព័ន្ធ នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង

- ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន ០៦ករណី ផ្ញើកំណត់បង្ហាញពាក្យបណ្ដឹង ចំនួន០៦ករណី ទទួលលិខិតឆ្លើយតប ពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០១ករណី និងឆ្លើយតប ទៅម្ចាស់បណ្ដឹងចំនួន០២ករណី កំពុងពិនិត្យ សិក្សាចំនួន០៧ករណី ព្រមទាំងទទួលឯកសារ ពាក្យបណ្ដឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធ បម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាប ចំនួន០៤ករណី
- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញ ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា ទូទាំងប្រទេស ចំនួន៦៩លើក ដើម្បីជួបពិភាក្សាការងារ ជាមួយអាជ្ញាធរមូលដ្ឋាន សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ជួបសំណេះសំណាល សាកសួរ សុខទុក្ខប្រជាពលរដ្ឋ ដឹកនាំក្រុមគ្រូពេទ្យ ស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺ ជូនប្រជា-ពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធ សមិទ្ធផលនានា តាមដានការអនុវត្ត គោល-នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពី ស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អ សេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អ នៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗ លើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុង ពិធីផ្លូវការផ្សេងសរុបចំនួន១២២លើក។

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
| --- | --- |
| - សម្តេចប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យប្រធានាធិបតីនៃប្រទេសហុងគ្រី ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃប្រទេសគុយបា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជាចំនួន០៥រូប និងប្រតិភូយុវជននៃសមាគមនារីយុវជនអាស៊ីអាគ្នេយ៍កម្ពុជាចំនួន៣៣រូប ចូលជួបជូនសារតាំង សវនាការ សម្តែងការគួរសម និងផ្តល់អនុសាសន៍<br>- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតឱ្យអនុប្រធានគណៈកម្មាធិការធនធានប្រជាជន និងបរិស្ថាននៃសភាប្រឹក្សានយោបាយប្រជាជនចិន និងគណៈប្រតិភូសហភាពសហព័ន្ធយុវជនកម្ពុជាចំនួន១៤នាក់ ចូលជួបសម្តែងការគួរសមនិងផ្តល់អនុសាសន៍ណែនាំ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញទៅចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៤១ នៅប្រទេសស៊ែប៊ី ចូលរួមកិច្ចប្រជុំលើកដំបូងស្តីពី ការបង្កើតបណ្តាញក្រុមសីលធម៌សមាជិកសភាហ្វ្រង់កូហ្វូនី នៅសភាវ៉ាល់ឡូនីនៃប្រទេសបែលហ្ស៊ិក ចូលរួម | - អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP)នៅប្រទេសស៊ែប៊ី និងអញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង<br>- បានរៀបចំទីកន្លែងជូនថ្នាក់ដឹកនាំព្រឹទ្ធសភាសម្រាប់ជូនសារតាំង សវនាការ និងសម្តែងការគួរសម ជាមួយភ្ញៀវអន្តរជាតិចំនួន០៨លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបជាមួយភ្ញៀវជាតិ និងអន្តរជាតិ ដែលមកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន០៥លើក<br>- បានថតចម្លងឯកសារចំនួន៣១ច្បាប់ អស់ក្រដាសចំនួន៣៤៣សន្លឹក<br>- បានរៀបចំសម្អាត តុបតែងលម្អសាល ផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងបម្រើសេវាភេសជ្ជៈ ក្នុងកិច្ចប្រជុំចំនួន១៦លើក មានអ្នកចូលរួមចំនួន៤៥៩នាក់<br>- បានធ្វើកំណត់បង្ហាញ កំណត់ទូត របាយការណ៍ លិខិតឆ្លើយតប បកប្រែឯកសារ និងឯកសារជំនួយស្មារតីពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច សង្គម សភាប្រទេសជាដៃគូ និងលិខិតផ្សេងៗជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងគណៈប្រតិភូនានារបស់ព្រឹទ្ធសភាចំនួន០៥លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់ ស្មើនឹង០៣ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក |

| | |
|---|---|
| កិច្ចប្រជុំអន្តរសភាតំបន់អាស៊ីអាគ្នេយ៍លើកទី១ និងវេទិកាអាស៊ីអាគ្នេយ៍លើកទី៣ ស្តីពី ការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) នៅព្រះរាជាណាចក្រថៃឡង់ដ៍។ | សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៣២លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន០៧លើក ស្មើនឹង១៤នាក់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៩លើក ស្មើនឹង២៥នាក់<br>- បានរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា និងចូលរួមកិច្ចប្រជុំនៅសាធារណរដ្ឋបារាំង និងព្រះរាជាណាចក្រថៃឡង់ដ៍ចំនួន០៣លើក។ |

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២២៦ច្បាប់<br>- បានប្រជុំពិនិត្យ និងវាយតម្លៃវឌ្ឍនភាពសមិទ្ធកម្មប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩និងផែនការសកម្មភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩<br>- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០១៩ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះ |

- ការងារគ្រប់គ្រងបុគ្គលិក៖
+ បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន២០៦ច្បាប់
+ បានរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលបឋមសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌថ្មីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
+ បានរៀបចំរចនាសម្ព័ន្ធ គោលការណ៍ និងគោលនយោបាយថ្មីៗ។
- ការងារបណ្តុះបណ្តាលធនធានមនុស្ស៖
+ បានបើកវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសចំនួន០៧វគ្គ មានសិក្ខាកាមសរុបចំនួន៦២នាក់ សិក្ខាសាលាក្រៅប្រទេសចំនួន០១លើក មានសិក្ខាកាមសរុបចំនួន១០នាក់។
- ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖
+ បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
+ បានប្រជុំបែងចែកថវិកាឆ្នាំ២០២០ របស់ព្រឹទ្ធសភាជូនក្រុមនយោបាយ និងរដ្ឋបាល
+ បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី ការរៀបចំថវិកាកម្មវិធីសម្រាប់អនុវត្តឆ្នាំ២០២០ ជាមួយអង្គភាពថវិកា
+ បានរៀបចំតភ្ជាប់បណ្តាញប្រព័ន្ធ (FMIS)
+ បានរៀបចំរបាយការណ៍ស្តីពី ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់

ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

\+ បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខា-សាលាផ្សេងៗ និងផ្គត់ផ្គង់សម្ភារអនាម័យ សម្ភារការិយាល័យ និងភេសជ្ជៈ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ការដ្ឋានព្រឹទ្ធសភាចំនួន៥៨សំណើ

\+ បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន២៩លើក មានអ្នកចូលរួមចំនួន៣០៨នាក់

\+ បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២២១លើក

\+ បានថតចម្លងឯកសារចំនួន៣,២០៣ច្បាប់ ចងក្រងធ្វើជាសៀវភៅចំនួន០១ក្បាល អស់ក្រដាសចំនួន២៦,៨៧០សន្លឹក ព្រមទាំងបានជួសជុលសម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន១៥លើក

\+ បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន៧២លើក ស្មើនឹង៨១នាក់ៗ

- **ការកសាង អភិវឌ្ឍន៍ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ៖**

\+ រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

| | |
|---|---|
| | + បានសាងសង់រានដែកប្រក់ដំបូលការបូណាត នៅខាងមុខសាលសិក្ខាសាលាខាងត្បូង និងបាំង ជញ្ជាំង Smart Board ក្រោមដំបូលអក្សរ W នៅខាងមុខបណ្ណាល័យ<br>+ បានជួសជុលកែលម្អអគារនាយកដ្ឋានរដ្ឋបាល និងសាងសង់បន្ទប់ទឹកខាងក្រោយអគារគណៈកម្មការទី១០ ព្រមទាំងប្តូរពិដានក្នុងបន្ទប់ទឹកនៅនាយកដ្ឋានព័ត៌មាន<br>+ បានកាត់ថ្នល់ពង្រីកសួន ជីករណ្តៅ រៀបខឿនថ្មម៉ាបថ្មី សម្រាប់ដាំដើមឈើនៅសួនចំនួន០២សួន នៅខាងមុខអគារ DEF និងគូសគំនូសចំណតរថយន្តឡើងវិញ<br>+ បន្តជួសជុលបណ្តាញអគ្គិសនី បណ្តាញទឹក ម៉ាស៊ីនត្រជាក់ ទ្វារចេញ-ចូល នៅសាលប្រជុំពេញអង្គ អគារក្រហម អគារ DEF អគារជប៉ុន និងសាលពិសេសធំ<br>+ បានកែលម្អសួនច្បារ និងបានរៀបចំដាំដើមឈើថ្មីក្នុងបរិវេណព្រឹទ្ធសភាចំនួន០៣លើក ស្មើនឹង ០៤ប្លង់<br>+ ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២៧គ្រឿង/លើក<br>+ បានសហការជាមួយក្រុមហ៊ុន Maintenances ត្រួតពិនិត្យដំណើរយន្តចំនួន០២លើក<br>+ សហការជាមួយក្រុមហ៊ុនកម្ចាត់សត្វកណ្តៀរ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោង |

| | |
|---|---|
| | ផ្សាយ និងថ្ងៃឈប់សម្រាកចំនួន៣២លើក<br>+ បានបង្កើត Email, Telegram ជាមធ្យោបាយ សម្រាប់ទទួល និងបញ្ជូនឯកសារ ជូនសមាជិក សមាជិកាព្រឹទ្ធសភា<br>+ បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៨៣គ្រឿង និងបាន Upload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មាន សុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងារ របស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភា សរុបចំនួន១៥៣ប្រធានបទ។<br>- **ការងារផ្សេងៗៈ**<br>+ បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព និងធ្វើហ្វុងអក្សរ ចងទង់ជាតិ ចងបដា ពាក្យស្លោក ចំនួន១២លើក<br>+ បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន ១៥០ប្រធានបទ<br>+ បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥៤លើក<br>+ បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងរាជកិច្ចចំនួន១២ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ អ៊ុតក្របសៀវភៅ បញ្ចូលសៀវភៅភាសាអង់គ្លេសក្នុងកម្មវិធី KOHA ចំនួន២២៧ក្បាល<br>+ បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន ៥៣ក្បាល។ |

**១- មុខងារនីតិកម្ម**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពី ការកំណត់ច្រកទ្វារព្រំដែនកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពី កិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់

២- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពី ការកំណត់ច្រកទ្វារព្រំដែនកាត់នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពី ការចៀសវាងយកពន្ធត្រួតគ្នា និងការបង្ការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

៣- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី ការបង្កើតសម្ព័ន្ធភាពថាមពលពន្លឺព្រះអាទិត្យ

៥-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពី សហជីព

៦-កិច្ចព្រមព្រៀងស្តីពី ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ

៧-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

៨- សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញ ជួបសវនាការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំកម្មវិធីជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងចូលរួមក្នុងពិធីផ្លូវការនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមសហការរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបសវនាការ សម្តែងការគួរសម និងជួបសំណេះសំណាលជាមួយឥស្សរជនជាន់ខ្ពស់ជាតិ និងអន្តរជាតិ

-ត្រៀមរៀបចំសិក្ខាសាលា [illegible]

-ត្រៀមរៀបចំវេទិកានៅខេត្តកំពង់ចាម ខេត្តកំពត និងខេត្តមណ្ឌលគិរី

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអគ្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ត្រៀមទៅបំពេញទស្សនកិច្ចសិក្សានៅសាធារណរដ្ឋបារាំង (ថ្ងៃទី២៩ ខែសីហា - ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩)

-ត្រៀមទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសអូស្ត្រាលី (ថ្ងៃទី២១-២៨ ខែវិច្ឆិកា ឆ្នាំ២០១៩)

-ត្រៀមចូលរួមជាមួយរដ្ឋសភា ដើម្បីរៀបចំ ASEP/ASEM ឆ្នាំ២០២០

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តការងារតាមដាន៖ ការស្នើសុំគោលការណ៍ស្តីពីរបបសន្តិសុខសង្គម(ប.ស.ស) និងរថយន្ត ០១គ្រឿងចុងក្រោយ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលរួមអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) អភិវឌ្ឍធនធានមនុស្សព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការជាក់ស្តែង

-ត្រៀមចុះធ្វើជំរឿនមន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងអ្នកហាត់ការនៃអគ្គលេខាធិការដ្ឋាន ឆ្នាំ២០១៩

-ចាត់ចែងការរៀបចំប្រទីបសម្រាប់បុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

-ត្រៀមរៀបចំថវិកា សម្ភារៈ និងគ្រឿងឧបភោគ បរិភោគ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភាឧបត្ថម្ភកីឡាករអុំទូក

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យសំខាន់ៗនានារួមមានៈ បុណ្យឯករាជ្យជាតិ បុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ទិវាសិទ្ធិមនុស្សអន្តរជាតិ និងពិធីបុណ្យជាតិផ្សេងៗទៀត

-ត្រៀមបោះពុម្ពដំណាច់ឆ្នាំៈ ប័ណ្ណជូនពរ ទិនានុលេខន៍ ប្រតិទិន និងប័ណ្ណរថយន្ត

-ត្រៀមបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

-ត្រៀមការងារបុគ្គលិកឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមការងារបណ្តុះបណ្តាលឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមការងារលទ្ធកម្មឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមរៀបចំបែងចែកកញ្ចប់ថវិកាឆ្នាំ២០២០សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ត្រៀមរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៩

-ត្រៀមរបាយការណ៍បែងចែក និងប្រើប្រាស់ថវិកាឆ្នាំ២០២០

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធFMIS

-ត្រៀមរៀបចំថវិកាតាមកម្មវិធីរួម និងតាមអង្គភាពថវិកាឆ្នាំ២០២០។

## III-សេចក្តីសន្និដ្ឋាន

ក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកក្នុងការបម្រើសេវាជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាលើសេវាទ្រទ្រង់មុខងារនីតិកម្ម ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងបើកសម័យប្រជុំលើកទី៤ ចំនួន០២លើក។ ចំពោះមុខងារតំណាង បានចុះរៀបចំវេទិកា និងអមដំណើរសមាជិកព្រឹទ្ធសភាចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ទន្ទឹមនឹងនេះការអភិវឌ្ឍស្ថាប័ន កសាងបានទីកន្លែង

ធ្វើការប្រកបដោយវិជ្ជាជីវៈ និងមានសុវត្ថិភាព ការបណ្តុះបណ្តាលបង្កើនធនធានមនុស្ស ហើយគាំទ្រ បន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធ ធនធានមធ្យោបាយ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ស្របតាមការរីកចម្រើននាពេលបច្ចុប្បន្ន។ ចំណុចធំមួយដ៏សំខាន់គឺ កិច្ចសហប្រតិបត្តិការអន្តរជាតិបានចូលរួមសន្និបាត IPU & ASGP នៅប្រទេសស៊ែប៊ី និងចូលរួមកម្មវិធីអន្តរជាតិផ្សេងៗដែលបានប្រព្រឹត្តទៅដោយរលូន។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

**អគ្គលេខាធិការ**

ងឹម សារិទ្ធ